# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 20 – I need more time
## មេរៀនទី២០៖ ខ្ញុំត្រូវការពេលថែមទៀត

*STUDY NOTES*

*ឯកសារជំនួយមេរៀន*

**តួអង្គ**

Rocky:

រ៉ុកឃី ៖ និស្សិតអន្តរជាតិ។

John:

ចន ៖ និស្សិតបរទេសរៀននៅសកលវិទ្យាល័យ។

Alan:

អេឡិន ៖ គ្រូបង្រៀនរបស់ចន។

**សាច់រឿង**

នៅក្នុងមេរៀននេះ ចន ទទួលបានដំណឹងទុក្ខព្រួយពីផ្ទះរបស់គាត់។ ហើយគាត់ក៏បាននិយាយជាមួយគ្រូរបស់គាត់អំពីការសុំពេលវេលាបន្ថែម។

**ព័ត៌មាន – ការចាប់ផ្តើមការប្រឡងតែងសេចក្តី**

ខាងក្រោមនេះ គឺជាព័ត៌មានគន្លឹះមួយចំនួន ដើម្បីជួយលោកអ្នកឱ្យចាប់ផ្តើមសរសេរតែងសេចក្តី។

- សូមមើលចំណងជើងតែងសេចក្តីរបស់លោកអ្នក បន្ទាប់មក គូសបន្ទាត់លើឃ្លាសំខាន់ៗ។ ការធ្វើបែបនេះ លោកអ្នកនឹងទទួលបានឆ្អឹងឬគម្រោងនៃការសរសេរតែងសេចក្តី។ ឧទាហរណ៍ "អ្វីដែលលោកអ្នកទទួលទាន នឹងហុចផលដល់លោក"។ សូមពិនិត្យនិងពិភាក្សាឱ្យបានលម្អិតលើនិន្នាការនៃរបៀបរបបចំណីអាហារនៅប្រទេសអូស្ត្រាលី នៅក្នុងពេល៣០ឆ្នាំកន្លងមកនេះ"។

  ឃ្លាប្រយោគសំខាន់ៗមានដូចជា ៖

- សុភាសិតដែលថា "អ្វីដែលលោកអ្នកទទួលទាន នឹងហុចផលដល់លោក" - លោកអ្នកត្រូវកំណត់ដោយផ្តល់អត្ថន័យជាសង្ខេប នៅខាងដើមតែងសេចក្តីរបស់លោកអ្នក។


© RadioAustralia/AMES 2008

- “និន្នាការចម្បងៗនៃរបៀបរបបចំណីអាហារ” មានន័យថា និន្នាការ ដែលមនុស្សភាគច្រើន ដឹងនៅពេលមានការចោទសួរ ឧទាហរណ៍ ការផ្លាស់ប្តូរទៅទទួលទានអាហារដែលមានកាកសរសៃច្រើន ឬអាហារដែលមានជាតិខ្លាញ់កូឡេស្តេរ៉ូលទាប។ ការពិភាក្សាលើនិន្នាការចំនួន៣ គឺគ្រប់គ្រាន់ហើយ ហើយនិន្នាការនីមួយៗ គួរសរសេរឱ្យបានមួយកថាខណ្ឌៗ។
- “៣០ឆ្នាំ”។ ប្រសិនបើមានការបង្ហាញអំពីពេលវេលា សូមផ្តោតទៅលើពេលវេលានោះ ព្រោះចំណុចនេះ គឺជាចំណុចសំខាន់។
- “ពិនិត្យពិភាក្សាឱ្យបានស៊ីជម្រៅ” មានន័យថា អ្នកត្រូវវាយតម្លៃនិន្នាការ និងផ្តល់ទស្សនៈរបស់អ្នកលើគំនិតទាំងនោះ។

**<u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>**

| | |
|---|---|
| To pull through | រួចពីស្លាប់  ឆ្លងកាត់ពេលវេលាលំបាកមួយគ្រា។ |
| Short notice | ការជូនដំណឹងដោយមានការប្រាប់ជាមុនក្នុងរយៈពេលមួយដ៏ខ្លី។ រយៈពេលតិចតួចរវាងការផ្សព្វផ្សាយឲ្យដឹងនិងពេលកម្មវិធីចាប់ផ្តើម។ |
| To sit  for an exam | ការចូលប្រឡងជាលក្ខណៈផ្លូវការ។ |
| To hope all goes well | បន់ស្រន់សូមឱ្យស្ថានការមានដំណើរល្អប្រសើរ។ |
| Take a seat | អង្គុយចុះ។ |
| A long weekend | ការឈប់សម្រាកចុងសប្តាហ៍ បន្ទាប់ពីមានថ្ងៃសម្រាកបុណ្យសាធារណៈជាបន្តទៀត ឬ ការឈប់សម្រាកចុងសប្តាហ៍ មុនថ្ងៃបុណ្យសម្រាកសាធារណៈដែលធ្វើឲ្យចុងសប្តាហ៍មានរយៈពេលវែង។ |

ABC Radio Australia
Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008

## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| ability | authorised | (to) concentrate |
| extension | fantastic | (to) happen |
| heart attack | hospital | ill |
| news | penalty | (to) request |

### ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence.

ចូរជ្រើសពាក្យដែលសាកសមបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទ ក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒

សូមគូសខ្វែងនៅក្នុងប្រអប់ពាក្យមួយសម្រាប់លេខនីមួយៗ ឧទាហរណ៍ ☒

1. Most teachers have stated that work stress was a problem __________ them.

   ☐ with ☐ of ☐ for ☐ to

2. In order _________ reduce stress we should first recognise its symptoms.

   ☐ for ☐ to ☐ of ☐ we

3. Training a teacher __________ a lot of time and money.

   ☐ takes ☐ take ☐ taking ☐ taken


© RadioAustralia/AMES 2008

4. Who _______________ if the teacher has to take time off due to stress.

☐ lost ☐ loss ☐ lose ☐ loses

5. When stress is ongoing, some negative effects may ___________

☐ results ☐ result ☐ resulting ☐ resulted

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

**The /v/ and /w/ sounds:** practise saying this tongue twister out loud:

**សូរសំឡេង /v/ និង /w/** ៖ សូមហាត់និយាយពាក្យដែលត្រូវប្រឹងពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

**"We'll invite Viv over for wine and veal."**

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| ព័ត៌មាន ៖ ថ្ងៃបុណ្យឈប់សម្រាកនៅប្រទេសអូស្ត្រាលី | http://www.australia.gov.au/Public_Holidays |

ចម្លើយសម្រាប់លំហាត់ទី 2: 1) for 2) to 3) takes 4) loses 5) result


© RadioAustralia/AMES 2008